

ក្រូឃ្មោក សិស្សខិល

NAÏVE MASTER AND HIS MISCHIEVOUS STUDENT





BW
Books World



មានរឿង១ដំណាលថា : មានភិក្ខុមួយអង្គគង់នៅវត្ត មានកូនសិស្សតែម្នាក់ឈ្មោះអាផ្លូញ។ អាផ្លូញខិលណាស់ គ្រូល្ងង់ណាស់ឆោតច្រើន គ្មានឧបាសកឧបាសិកាណារាប់អានយកចង្ហាន់ស្លាបារី ទៅប្រគេន ឬ និមន្តលោកនោះមកឆាន់ផ្ទះដល់ម្តងឡើយលោកនោះក្រលំបាកពន់ពេក តែលោកមានដំរីមួយ។

A legend recounts that: there was a monk at a pagoda with a lone disciple named Phlaunch. The boy was very mischievous while the monk so naïve that no devotees, both male and female, were sympathetic to either bringing him the offerings or inviting him to have meals at their home. He lived a hard life, and had an elephant.






ថ្ងៃមួយលោកនោះពិចារណាថា "សព្វថ្ងៃនេះគ្មានឧបាសក ឧបាសិកា គេប្រគល់វត្ថុអ្វីឆាន់សោះ បើដូច្នោះគួរអញទិញវត្ថុផ្សេងៗយកមកទុកឆាន់កុំឱ្យលំបាក "។ គិតដូច្នោះហើយក៏ប្រាប់កូនសិស្សថា "អាផ្លូញឯងចាប់ដំរីមក ហើយឯងទៅផ្សារនឹងអញរកទិញវត្ថុផ្សេងៗយកមកទុកឆាន់"។ កូនសិស្សទៅចាប់ដំរីបានមកគ្រូនិងសិស្សក៏ឡើងជិះដំរីទៅផ្សារ ។

One day the monk thought to himself that everyday no one offered him the alms, so to make thing easy, why not buying some stuff to store for meals. With the idea, he told his novice: "Phlaunch! Go and get the elephant. Come with me to the market to get something to be used as food". The novice got the animal, and the two headed for the market on the elephant.

លុះទៅដល់គ្រូប្រាប់កូនសិស្សថា "ឯងទិញវត្ថុអ្វីដែលទុកបានយូរមិនខូច" ។ អាផ្លូញ្ជាសិស្សក៏ទិញអំបិលមួយចុងច្រកការុងស្រែច។ គ្រូឃើញសួរថា "ហេតុដូចម្តេចក៏ឯងទិញតែអំបិល មិនទិញត្រីឆ្អែរត្រីងៀតផង ?" ។ កូនសិស្សទូលថា "អំបិលទុកបានយូរ មិនចេះខូច បានជាខ្ញុំព្រះករុណាទិញ" ។ គ្រូឆោតល្ងង់ណាស់ក៏ស្ងៀម។

On arrival, the master said to the disciple: "Buy anything that can last long, unspoiled". Phlaunch got a sack of salt. The master asked why he didn't buy dried fish, instead of salt. The novice replied: "Salt can be kept for a long period without getting spoiled. That is why I bought it". Because of his stupidity, the monk did not utter a word.








គ្រូឡើងបរដំរីមកវិញ សិស្សរែកអំបិលដើរពីក្រោយ ដល់ពាក់កណ្តាលផ្លូវគ្រូមើលទៅសិស្ស ឮសូរដងរែកដូចជាស្រួលក៏សួរថា "អាផ្លូញ! អញ្ចឹមើលទៅឯងរែកអំបិលដូចជាស្រួលឬយ៉ាងណា?"។ សិស្សទូលថា "ព្រះករុណា! ស្រួលណាស់ហើយស្រាលផង "។ លោកគ្រូប្រាប់សិស្សថា "ឯងជិះដំរីវិញអញរែកអំបិលដើរក្រោយ"។ លោកគ្រូថាហើយ ចុះពីលើដំរីមក សិស្សក៏ឡើងជិះដំរីទៅ។ លោកគ្រូប្រាប់ថា "ឯងបរដំរីទៅចាំអញមួយឈើមុខ"។ សិស្សបរដំរីទៅដល់មួយឈើក៏មិនឈប់ចាំគ្រូ បររហូតដល់វត្ត។

The master rode the elephant back home while the disciple walked behind carrying the salt. Half way, the monk looked at his boy. The sound of the carrying pole made him think that it was comfortable to have it on the shoulder. He asked: "Eh boy! Do you feel comfortable with that pole on your shoulder". The disciple replied: " My dear master! Very comfortable, and it is light". The monk then said: "You ride the elephant. Let me carry the salt". He then climbed down the animal and the disciple took over. The master told his student to wait for him under a tree ahead. The student did not do as his master told him. Instead, he rode the elephant as far as the pagoda.



លោកគ្រូរែកអំបិលដើរតាមក្រោយ ដោយអំបិលនោះធ្ងន់ណាស់ លោកគ្រូរែកឈប់ៗ បែរមើលទៅសិស្សមិនឃើញក៏គិតថា "ចាំក្រោយសឹមនាំសិស្សមកយក" ហើយយកអំបិលទៅលាក់ក្នុងព្រៃ មុននឹងលាក់លោកគិតថា "ទីនេះបើប្រសិនជាមានគេដើរមកចំរកឃើញគេនឹងយកអំបិលនេះអស់មិនខាន គួរតែរកទីណាដែលកំបាំងភ្នែកអ្នកទាំងពួង គឺមានតែក្នុងទឹកទើបគេ មើលមិនឃើញ " ហើយក៏យកអំបិលទាំងពីរការុងទៅលាក់ទុកក្នុងទឹក ហើយដើរទៅ លុះដល់សួរសិស្សថា "ហេតុដូចម្តេចក៏ឯងមិនចាំអញ ?" ។ សិស្សទូលថា "ខ្ញុំព្រះករុណាបរដីរមកប្រុងចាំលោកគ្រូដែរតែដីរមិនព្រមចាំសោះ អង្វរដូចម្តេចក៏វាមិនព្រម វាប្រឹងដើរដល់វត្តទើបឈប់" ។ សិស្សសួរគ្រូថា "លោកគ្រូទុក អំបិលនៅឯណា?" គ្រូប្រាប់ថា "អញលាក់ទុកនៅទីឯណាអញកាច់ដើមឈូកដោតជាសំគាល់" ។

The master carried the salt behind. As the salt was weighty, he frequently took a rest. With his student not in sight, he then thought about getting his disciple to come back and take the salt. When he was about to hide it in the bush, an idea just flashed out in his mind. He thought that if he did not find a secure place to hide the salt, and by accident when someone passed by and came across it, he would take them all. So he thought that the only place that no one could spot it easily was the river. He hid the two sacks of salt in the river and reached the pagoda, where he asked his novice: "Why didn't you wait for me?". The disciple answered: "My dear master! I rode the elephant and was indeed willing to wait for you. But the animal did not. I begged it. But he ignored and kept going on until we arrived at the pagoda". The novice asked his master: "Where did you put away the salt?". The monk replied: "I hid it where I marked with a lotus plant".

ព្រឹកឡើងនាំកូនសិស្សទៅយកអំបិលវិញលុះដល់ប្រាប់សិស្សថា "អញលាក់ទុកក្នុងត្រពាំងនេះ" ។ សិស្សលាន់មាត់ថា "ម៉ែអើ! វារលាយអស់ហើយ! "។ អាផ្ងួញក៏ចុះទៅយកអំបិលលើកការុងទាំងពីរឡើងរលាយអស់គ្មានសល់ ចំណែងដែលចងមាត់ការុងដាច់អស់ ឃើញឯត្រីកញ្ឆុះមួយនៅក្នុងការុងនោះ។ សិស្សទូលលោកគ្រូថា "មានត្រីកញ្ឆុះមួយនៅក្នុងការុង វាស៊ីអំបិលអស់ហើយ"។ យកត្រីនិងការុងប្រគេនគ្រូមើល ។

In the next morning, the monk returned with his novice to collect the salt. He said: " I hid it in the river". The student exclaimed: " My god! It all dissolves". Phlaunch took the two sacks of salt out of the water, only to find out it all dissolves, and the string that was used to tight up the sacks also broke apart. Only a lone fish was found in the sack. The novice told the master that the fish in the sack ate up the salt. He showed the fish and the sacks to his master.









លោកគ្រូឃើញត្រីខឹងណាស់ក៏ទះកំផ្លៀងមុតដៃនឹងធ្មង់ត្រីជាប់។ ពិសត្រីចាប់ពើតឈឺខ្លាំងពេកលោកគ្រូថា "ឯងចាប់ត្រីដកធ្មង់វាឆាប់ត្បិតអញឈឺណាស់"។ សិស្សក៏ចាប់ដកទាញស្ទើរតែមិនរួច។ លុះដករួចឈាមហូរជាខ្លាំងពិសត្រីរឹតតែឈឺខ្លាំងឡើង លោកគ្រូនាំកូនសិស្សទៅវត្តវិញយកទាំងការុង និងត្រីកញ្ចុះទៅផងដល់វត្តប្រាប់សិស្សថា "អាផ្លូញ ឯងដាំបាយមួយឆ្នាំង អាំងត្រីកញ្ចុះនេះឱ្យឆ្អិនជាឆាប់អញនឹងឆាន់"។ លុះពិសអន់ចាប់ពើត លោកគ្រូក៏សំងំឈឺងលក់ទៅ។

The master was so irritated that he slapped the fish in the face, but only had his hand pierced with the fish barbs. The fish venom caused severe pain, making it so hard for the master to stand. He then shouted: "Pull the barb off my hand. It hurt severely". The barb got stuck so deep that it made it hard for the student to get it out. Once it was out, the blood started to come out so heavily that it caused even more painful. Both the master and the student returned to the pagoda, bringing with them the sacks and the fish. At the pagoda, the monk said to his novice: "Phlaunch, let cook a pot of rice and have the fish grilled. I will have them". After the pain caused by the venom died down, the master felt into a deep sleep.








ឯអាផ្លូញក៏ដាំបាយអាំងត្រីឆ្អិន ហើយបរិភោគអស់ទុកតែបាយ
មួយពំនូកនិងឆ្អឹងត្រីក្តុងចានគ្រប តែវាគ្របមិនឱ្យជិត។ លោកគ្រូ
ភ្ញាក់ឡើងប្រាប់សិស្សថា "ឯងយកបាយ និងត្រីមកឆាន់ " អាផ្លូញ
ក៏ធ្វើជាកិរិយាដូចជាទៅយកបាយប្រគេនគ្រូ ចេញមកវិញទូលថា
"បាយ និងត្រីរុយយកស៊ីអស់ទៅហើយ នៅសល់តែមួយពំនូក
និងឆ្អឹងត្រី "លោកគ្រូជឿ ឥតសង្ស័យដោយឆោតល្ងង់ ក៏
ឱ្យរំពាត់ផ្តៅមួយមកសិស្សថា "ឯងវាយរុយកុំឱ្យវានៅ
លើកុដិ " អាផ្លូញ ជាសិស្សក៏វាយរុយមិនឈប់ ។ គ្រា
នោះមានរុយទុំច្រមុះគ្រូ វាយទៅៗមិនត្រូវរុយ ត្រូវ
ច្រមុះគ្រូបែកឈាមហូរខ្ជាយ។ សិស្សភ័យណាស់រត់ទៅ
ដល់ផ្ទះនិយាយប្រាប់ឪពុកម្តាយតាមរឿង ។ ឪពុកម្តាយ
ប្រាប់កូនឱ្យមកវត្តវិញ កូនប្រកែកមិនព្រមមក។ លោកគ្រូទៅតាមក៏វាមិនហ៊ានមក
ដោយខ្លាចគ្រូវាយ។

Plaunch cooked the rice and grilled the fish, He ate all the food, leaving only a small piece of rice and fish bones in the bowl and covered it, but not completely closed. Waking up, the monk asked his disciple to bring him rice and the fish. Phlaunch behaved as if he went and fetch the meal for the monk. When his master emerged, he said: "The fly eats up the rice and the fish. Only a small piece of rice and fish bone remain. The monk believed it and without any doubt, he gave the disciple a rattan rod and said: "Hit and do not let any fly in the abbot". Phlaunch then would spare no flies. Suddenly, a fly pierced on the master's nose. Urged by the monk, he hit it. The fly escaped, and he accidently landed on his master's nose, which started to bleed afterward. Felt frightened, he rushed to his parents' house and recounted the incident. The parents urged his son to get back to the pagoda, but he refused. The monk went and told him to return, still he did not for fear being hit by his master.

ថ្ងៃមួយលោកគ្រូតាំងពីធីសូត្រមន្ត អាគមស្នេហ៍បន្ទន់ចិត្តសិស្សឱ្យមក។ អាផ្លូញ្ជាសិស្សបានដឹងថាគ្រូ តាំងពីធីសូត្រមន្តអាគមស្នេហ៍ ដូច្នោះ ក៏មកវត្តវិញ ដើម្បីឱ្យគ្រូជឿថាស្នេហ៍ពូកែ។ លុះដល់វត្តវិញដើរលបៗចូលទៅឃើញគ្រូកំពុងតែអង្គុយសូត្រមន្តអាគមស្នេហ៍ក៏សួរលោកថា "លោកគ្រូធ្វើអ្វី?" ។ គ្រូកុហកថា "អញសូត្រមន្តអាគមបំបាំងខ្លួន ព្រោះអញទើបរៀនពីគេ"។ ហើយលោកគ្រូគិតថា "ស្នេហ៍អញពូកែមែនបានជាសិស្សអញវាមក "។ លុះព្រឹកឡើងសិស្សដាំបាយធ្វើម្ហូបស្រេច ទូលថា "ចង្ហាន់ឆ្ងិនហើយ" ។ លោកគ្រូថា "បើដូច្នោះឯងលើកយកឱ្យអញ ឆាន់ "។ អាផ្លូញ្ជាក៏លើកមកប្រគេន ធ្វើជាមើលមិនឃើញ ដាក់ថាសទៅលើក្បាលគ្រូៗស្រែកថា "អាផ្លូញ្ជា! ហេតុម្តេចក៏យកថាសមកដាក់លើក្បាលអញ?" ។ សិស្សទូលថា " ខ្ញុំព្រះករុណាមើលមិនឃើញ" ។ លោកគ្រូងាកចេញ អាផ្លូញ្ជាក៏ដាក់លើក្បាលគ្រូទៀត។ លោកគ្រូថា "អាផ្លូញ្ជឯងដាក់ថាសលើក្បាលអញទៀតហើយ"។ សិស្សថា "ខ្ញុំព្រះករុណា សូមទោសព្រោះមើលមិនឃើញ"។ លោកគ្រូជឿថា អញរៀនស្នេហ៍ៗ ពូកែប្រាកដឥឡូវអញកុហកវា ថាតាំងពីធីមន្តអាគមបំបាំងខ្លួនវិញ ក៏ទៅជាពូកែគេមើលមិនឃើញប្រាកដមែនគួរទន្ទេញឱ្យចាំកុំឱ្យភ្លេច ។

19One day the monk hold a ritual to cast magic spell to lure back his disciple. Phlaunch was aware of what his master was doing. To make his master convinced that his magic did work, he came back to the pagoda. Arriving at the pagoda, he sneaked in quietly. He saw his master sit reciting the magic spell and asked: "What are you doing, master?". The monk lied: " I am reciting the magic to make myself invisible. I have just learned from somebody". The monk thought to himself: "My charming magic is powerful. That is why my student gets back". When the morning came, the disciple finished preparing the meal. He said: "The meal is ready". The monk replied: "So bring me the food". Phlaunch brought food on a tray for the monk. He pretended not see his master and placed it on his master's head. The monk asked: "Phlaunch! Why do you put the tray on my head?". The student said: "I cannot see you". The master turned aside, and Phlaunch again placed it on his master's head. The monk said: "Phlaunch! You have it on my head again". The novice said: "Sorry! I cannot see you". That made the master believe that his charming witchcraft work well. And now after he lied to his student about his invisibility magic, he found out that it was equally effective. So he started to learn it by heart.






អាផ្លូញលុះប្រគេនចង្ហាន់គ្រូៗឆាន់រួចហើយ វាលើកមកបរិភោគខ្លួនវា។ ថ្ងៃក្រោយ មានឧបាសកគេនិមន្តលោកគ្រូទៅឆាន់ឯផ្ទះ ។ អាផ្លូញទូលថា "បើលោកគ្រូនិមន្តទៅឆាន់ផ្ទះកុំស្លៀកស្បង់ឱ្យចាស់ខូចឥតអំពើឃ្លុំតែចីពរបានហើយគេមើលមិនឃើញទេ" ត្បិតលោកគ្រូចេះមន្តអាគមបំបាំងខ្លួនពូកែណាស់ អ្នកណានឹងមើលឃើញ" គ្រូជឿក៏ធ្វើតាមពាក្យសិស្ស ។ លុះព្រឹកឡើងលោកគ្រូប្រាប់សិស្សថា " ឯងតាមអញទៅឆាន់ឯផ្ទះឧបាសក" រួចលោកឃ្លុំតែចីពរមិនស្លៀកស្បង់ដោយគិតថា "ឃ្លុំតែចីពរបានហើយព្រោះមន្តអាគមអញពូកែណាស់ នរណានឹងមើលកេរ្តិ៍ខ្មាសឃើញ" រួចនាំកូនសិស្សទៅ ។

Phlaunch had the left-over after offering the meal to the monk. One day, devotees invited the monk to have lunch at their home. Phlaunch said: " If you go to have lunch outside, don' t wear the robe in order not to make it worn out. Just put on the outer clothing. No one will be able to see you because you learn a powerful magic that can make you invisible". The master believed what was said by his disciple. In the morning, the monk told his student to come along with him to have meal at devotees' house. He worn only a scant outer clothing, thinking that this piece of clothing was enough because his magic was so powerful that no one could see his private parts. He then set off with his novice.


លុះទៅដល់ឧបាសកនិមន្តឡើងលើផ្ទះហើយ គេលើកចង្ហាន់មក ដើម្បីប្រគេនលោកឆាន់ ដោយលោកមិនបានស្បៀកសង្ឃ៍ អង្គុយមិនស្រួលងាកឆ្វេងងាកស្តាំ ក៏លេចកេរ្តិ៍ខ្មាស កណ្តាលវាល។ ឧបាសកឃើញដូច្នោះគេក៏នាំគ្នាសើចហ៊ោរលាន់។ លោកគ្រូពុំទាន់បានឆាន់ចង្ហាន់មានចិត្តខ្មាសគេណាស់ ក៏ចុះពីផ្ទះត្រឡប់មកវត្តវិញ ជេរបន្ទោសសិស្សថា "អាឯងមិនឱ្យអញស្បៀកសង្ឃ៍ ឥឡូវអញខ្មាសគេណាស់ " អាផ្លូញ្ញូលថា "លោកគ្រូកុំខ្ញាល់នឹងខ្ញុំព្រះករុណា រឿងនេះប្រហែលជាខុសត្រណមទេឬ? " ។ លោកគ្រូសួរថា "ឯងឃើញអញខុសត្រណមដូចម្តេច ?"។ អាផ្លូញ្ញសួរថា "កាលគ្រូនិមន្តទៅឆាន់ផ្ទះឧបាសក និមន្តទៅផ្លូវណា ?" ។


On arrival, the devotees invited him onto the house. The food were brought before him. As he did not put on the robe and was carelessly seated, at one point turning to the left and at the other to the right, the monk then got his private parts exposed. The audience burst into laughter. The monk did not have the food, and feeling embarrassed, he left and returned to the pagoda, blaming his novice: "You told me not to put on the robe, and now I feel embarrassed". Phlaunch replied: " Don't be angry with me. There must be something wrong with your treatment of the taboo". The master asked: " Can you tell me how I acted against the taboo?". Phlaunch asked: "Which road did you take when you went to the devotees' home?".



លោកគ្រូប្រាប់ថា "អញ្ចុះកាលទៅចេញផ្លូវ កើត " ។ សិស្សថា "ឱ! ច្បាស់ជាលោកគ្រូខុសត្រណមហើយ " ។ ថ្ងៃមុនលោកគ្រូ ប្រាប់ខ្ញុំព្រះករុណាថា "បើរៀនមន្តអាគមទាំងពួងត្រូវឱ្យតមស៊ីផ្លែស្តី សូម្បីតែមុជក្រោមដើមស្តីក៏មិនបាន វាសាបមន្តអាគមឥឡូវលោកគ្រូមុជក្រោមដើមស្តីបានជាខុសត្រណមសាបអាគមអស់ ហេតុនេះបានជាគេឃើញកេរ្តិ៍ខ្មាសលោកគ្រូ" ។

The master replied: "When I left, I took the eastern road". The student said: " Oh dear! You might act against the taboo". The other day, you told me that when you learn all magic spells, you must refrain from eating star fruits, let alone walking under the star fruit trees. This will let all the spells just gone away. Your spell vanishes because you walked under the star fruit tree. That is why everyone could see your private parts".





លោកគ្រូបានស្តាប់ដូច្នោះហើយក៏ថា " ឱ! អាផ្លូញអញភ្លេចតមបានជាយ៉ាងហ្នឹង ឯងថានោះពិតប្រាកដហើយ" ។ លោកគ្រូនោះដោយឆោតល្ងង់ក៏ជឿជាក់ឥតសង្ស័យ ។ តាំងពីនោះមកអាផ្លូញជាសិស្សនៅបម្រើគ្រូដោយសុខសប្បាយ ។ **ស្ងួតស្ងាប់ វៀចវែមានភ័ព្ធ អាយុយឺនយូរ ។**

ចប់

The end

After hearing this, the master agreed: " Yes! Phlaunch, I forgot about the taboo. That is why I got a problem. You are right". Because of his stupidity, his doubt had gone. Since then, Phlaunch had continued to attend to his master happily. Being gentle would have you killed!Being cunning would make you lucky enough to live longer!